អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## ការតែងតាំងសហព្រះរាជអាជ្ញាអន្តរជាតិស្តីពី

នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៩ បន្ទាប់ពីមានការជ្រើសតាំងឲ្យឈរឈ្មោះរបស់ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិរួចមក ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៃ កម្ពុជា បានតែងតាំងជាបណ្តោះអាសន្ន លោក **វីលាម ស្មីត** (William SMITH) ជនជាតិអូស្រ្តាលី ជា **សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី** នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការតែងតាំងរបស់គាត់ត្រូវចូលជាធរមាននៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៩ ។ ការតែងតាំងនេះ ត្រូវបានធ្វើឡើងក្នុងរយៈពេលរង់ចាំសេចក្តីសម្រេចអំពីការដាក់ជំនួសជាអចិន្ត្រៃយ៍ សម្រាប់មុខតំណែងសហព្រះរាជអាជ្ញាអន្តរជាតិបច្ចុប្បន្ន លោក **រ៉ូប៊ឺត ពីទីត** (Robert PETIT) ដែលការលាលែងពីមុខតំណែងរបស់គាត់ក៏ត្រូវចូលជាធរមាន ក្នុងថ្ងៃដូចគ្នានេះដែរ ។ ការជ្រើសតាំងឈរឈ្មោះចំនួនពីររូប សម្រាប់មុខតំណែងអចិន្ត្រៃយ៍បានត្រូវបញ្ជូនដោយ អគ្គលេខាធិការអង្គការសហប្រជាជាតិ ទៅ រាជរដ្ឋាភិបាលកម្ពុជា រួចហើយដើម្បីសុំសេចក្តីសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

លោក ស្មីត បានធ្វើជា សហព្រះរាជអាជ្ញារងអន្តរជាតិ នៃ អ.វ.ត.ក ក្នុងរយៈពេល៣ ឆ្នាំកន្លងទៅនេះ ។នៅចន្លោះឆ្នាំ១៩៩៥ និងឆ្នាំ២០០៦ លោក ស្មីត ធ្លាប់បានធ្វើការជាអយ្យការជំនុំជម្រះ ជាមន្ត្រីច្បាប់ និងជាអ្នកវិភាគ នៅតុលាការព្រហ្មទណ្ឌសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) នៅទីក្រុងឡាអេ ។ កាលពីមុននោះ លោក ស្មីត បានអនុវត្តវិជ្ជាជីវៈផ្នែកច្បាប់ព្រហ្មទណ្ឌនៅប្រទេសអូស្ត្រាលីភាគខាងត្បូងក្នុងនាមជាមេធាវីការពារក្តីនិងជាស្មាក្តី ព្រមទាំងជា រដ្ឋអាជ្ញាមួយរូបសម្រាប់នាយកដ្ឋាននគរបាលនៃ ប្រទេសអូស្ត្រាលី ភាគខាងត្បូង ។ លោក ស្មីត បានទទួលការសិក្សាអប់រំនៅសកលវិទ្យាល័យ អាដីឡេត (Adelaide) ដែលនៅទីនោះគាត់បានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកច្បាប់ និងផ្នែកអក្សរសាស្ត្រ ។ គាត់ក៏បានទទួលផងដែរ នូវបរិញ្ញាប័ត្រជាន់ខ្ពស់ (អនុបណ្ឌិត) ផ្នែកច្បាប់អន្តរជាតិ ពីសកលវិទ្យាល័យ ឡីដឹន (Leiden University) នៅប្រទេសហុល្លង់ ៕

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**


លោករាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855 (0) 12 488 156
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោកឌីម សុវណ្ណារ៉ុំ
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855 (0) 12 488 094
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោកឡាស អូលសិន
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855 (0) 12 488 023
ទូរស័ព្ទលេខ +855 (0) 23 219 814 លេខបន្ត 6169
សារអេឡិចត្រូនិច olsen@un.org

លោកស្រី យូកូ មេដា
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ: +855 (0) 12 488 319
ទូរស័ព្ទលេខ: +855 (0) 23 219 814 លេខបន្ត 6139
សារអេឡិចត្រូនិច: maeday@un.org